## ១- ឈ្មោះ និង ការចាត់ថ្នាក់នៃប្រភេទឈើ

ឈ្មោះក្នុងស្រុក : ស្ដៅ

ឈ្មោះវិទ្យាសាស្ត្រ : *Azadirachta indica* **A. Juss.**

គ្រួសារ : **Meliaceae**

ចំណាត់ថ្នាក់ជាតិ : ឈើក្រៅលំដាប់ថ្នាក់

## ២- ការរាយប៉ាយក្នុងធម្មជាតិ និង ទីកន្លែងដុះដាល

ការពិពណ៌នាអំពីដំណុះធម្មជាតិមានការស្មុគស្មាញ ដោយសារស្ដៅត្រូវបានដាំដុះយ៉ាងទូលំទូលាយ ប៉ុន្តែប្រភេទនេះត្រូវបានរកឃើញថា មានប្រភពដើមពីព្រៃល្បោះហួតហែងនៃបណ្ដាប្រទេសអាស៊ីដូចជា កម្ពុជា ថៃ ភូមា ស្រីលង្កា ម៉ាឡេស៊ី ឥណ្ឌាភាគឥសាន្ត ប៉ាគីស្ថាន និង ឥណ្ឌូនេស៊ី។ ការដាំដុះស្ដៅបានរាលដាលយ៉ាងខ្លាំងនៅតំបន់ស្ងួតក្រៀមក្រោះនៃប្រទេសឥណ្ឌា និង ភូមា។ នៅតំបន់ស្ងួតក្រៀមក្រោះ និងតំបន់ដែលមានសំណើមបង្គួរនៃប្រទេសក្នុងតំបន់អាស៊ី ទ្វីបអាហ្វ្រិក ស្ដៅត្រូវបានដាំជាចំការធំៗ ហើយថ្មីៗនេះត្រូវបានដាំក្នុងប្រទេស អូស្ត្រាលី អាមេរិកឡាទីន និង អាមេរិកខាងត្បូង។ ស្ដៅដុះនៅតំបន់ដែលមានរបបទឹកភ្លៀងធ្លាក់ប្រចាំឆ្នាំពី៤៥០-១១៥០ម.ម។ ប៉ុន្តែមិនអាចធន់នឹងភាពត្រជាក់ ឬនៅកន្លែងដែលមានទឹកកកបានទេ។ ដើមស្ដៅអាចដុះនៅតំបន់ក្ដៅ( ត្រូពិច) ឬតំបន់ត្រជាក់មធ្យម ហើយអាចធន់ទ្រាំនឹងរដូវប្រាំង (រដូវរាំងស្ងួត) ដែលអូសបន្លាយពេលដ៏វែងបាន។ ស្ដៅដុះច្រើននៅគ្រប់កន្លែងគឺនៅរយៈកំពស់ ០-៧០០ ម ធៀបនឹងនីវ៉ូទឹកសមុទ្រ ប៉ុន្តែជួនកាលអាចដុះនៅតំបន់ដែលមានកំពស់ដល់ ១៥០០ម ផងដែរ។ ស្ដៅអាចដុះនៅក្នុងតំបន់ដែលមានកំដៅដល់ ៤៤ អង្សាសេ។ ប្រភេទនេះមិនទាមទារគុណភាពដីល្អទេ អាចដុះលូតលាស់បាននៅគ្រប់ទីកន្លែងនៅលើដីស្ទើរគ្រប់ប្រភេទរួមមានដីស្ងួត ដីឥដ្ឋ ដីថ្ម និង ដីភក់ ប៉ុន្តែមិនអាចដុះបាននៅលើដីដែលមានទឹកដក់ជាប្រចាំ ឬ ដីខ្សាច់ជ្រៅបានទេ។ ម្យ៉ាងទៀតមិនអាចទ្រាំបានទៅនឹងដីដែលមានជាតិប្រៃ ដីជាំទឹក ឬដីឥដ្ឋប្រេះក្រហែងទេ។ ជារួម ប្រភេទនេះត្រូវការដុះនៅលើដីដែលមានកំរិត pH = ៥-៧។

## ៣- ការប្រើប្រាស់

ស្លឹកស្ដៅសំរាប់ជាអាហាររបស់គោ ក្របី ចំណែកត្រួយ និង ផ្កាជាអាហារដ៏ល្អសំរាប់មនុស្ស។ ដើមស្ដៅផ្ដល់អុស និង ឈើប្រើប្រាស់ជាសសរបង្គោលដោយសាច់ឈើមិនងាយពុក មិនចាញ់ការយាយីរបស់សត្វល្អិត។ ឈើស្ដៅស្ថិតជាងឈើម៉ៃសាក់មានគុណភាពល្អសំរាប់សំណង់ និងគ្រឿងសង្ហារឹម។ ដើមស្ដៅដែលលូតលាស់ពីខ្នែងរហ័សជាងដើមលូតលាស់ពីគ្រាប់។ គ្រាប់ស្ដៅមានជាតិប្រេងដែលអាចប្រើសំរាប់ដុតបំភ្លឺ និងធ្វើជាប្រេងរំអិលសំរាប់ម៉ាស៊ីន។ ប្រេងស្ដៅចាំបាច់បំផុត សំរាប់ធ្វើសាប៊ូរម្ងាប់មេរោគ ប្រើក្នុងឧស្សាហកម្មថ្នាំពេទ្យ និងសំរាប់ផ្សំធ្វើជាគ្រឿងសំអាង។ ស្លឹក គ្រាប់ និងសំបក សំរាប់ផ្សំថ្នាំឱសថបុរាណព្យាបាលមនុស្ស ឬសំលាប់សត្វល្អិត។ ជាពិសេស ប្រភេទនេះ ផ្ដល់ម្លប់ ជារបាំងខ្យល់អភិរក្សដី កែប្រែគុណភាពដីដែលស្ងួតក្រៀមក្រោះ។

## ៤- លក្ខណៈរុក្ខសាស្ត្រ

- ដើម: ជាប្រភេទឈើមានទំហំមធ្យមមានកំពស់ ១៥ម ជួនកាលអាចមានកំពស់ដល់ ២៥ម ដោយតួដើមដែលត្រង់ល្អមានប្រវែងខ្លី និងមានមែកសាខាលាតត្រដាងតាមបណ្ដោយដើមមានសណ្ឋានក្រាស់ បង្កើតបានជាកន្ទ្រាមស្លឹករាងមូល ឬរាងពងក្រពើ។ ជាទូទៅ ស្ដៅជារុក្ខជាតិបៃតងជានិច្ចបើដុះនៅលើដីសើម ហើយបើដុះនៅតំបន់ដែលក្ដៅខ្លាំង និងតំបន់ដែលមានរដូវប្រាំងរយៈពេលវែង នោះវាជ្រុះស្លឹកក្នុងមួយឆ្នាំម្ដង។ សំបកស្ដៅក្រាស់ល្មម ពណ៌ប្រផេះ ពេលចាស់សំបកប្ដូរពណ៌ទៅជាប្រផេះក្រម៉ៅ។ ខ្លឹមស្ដៅ ពណ៌ក្រហម ហើយជាប់មាំល្អ។

- ស្លឹក: មានទំហំតូច ជាស្លឹកសមាសស្លាបគូ មានស្លឹកពី ៧-១៧គូ ដែលមានរាងទ្រវែងស្រួច ឬដូចចុងលំពែងដែលកោងដូចដងធ្នូ គល់ស្លឹករងិបរង៉ុប ហើយគែមស្លឹកដូចធ្មេញរណារ។ ស្លឹកមានបណ្ដោយ៦-៨ស.ម ទទឹង១-៣ស.ម។ ជាទូទៅ ដើមស្ដៅមានស្លឹកច្រើនប្រកបដោយមែកសាខា។

## ៥- ការពិពណ៌នាអំពីផ្កា ផ្លែ

- ផ្កា: ជាប៉ានីកូល (Panicle) មានប្រវែង ១០-៣០ស.ម ហើយមាន ចំនួនច្រើន។ ផ្កា ស្ដៅតូចៗមានពណ៌ពងមាន់ស។

- ផ្លែ: មានរាងអេលីប មានគ្រាប់រឹង បណ្ដោយផ្លែមាន ១,២-២ស.ម ។ ពេលខ្ចីមានពណ៌បៃតង ពេលទុំមានពណ៌លឿង។ សំបកផ្លែផ្នែកខាងគល់ជាប់ សណ្ដង់ស្ដើងតែមាំ ហើយសាច់ផ្លែមានទឹកដមច្រើន។

-គ្រាប់: ក្នុងមួយផ្លែមានគ្រាប់មួយ ហើយកំរមានពីរណាស់។ គ្រាប់ស្ដៅនីមួយៗមានទំហំ និងទំងន់ខុសៗគ្នា តាមទីកន្លែង និងប្រភពនៃគ្រាប់។ តាមពតិមានដែលអាចរកបានបង្ហាញថា នៅប្រទេសសាហេល (Sahel) ក្នុងមួយគីឡូក្រាមមាន១៧០០គ្រាប់ ហើយនៅប្រទេសឥណ្ឌាក្នុងមួយគីឡូក្រាមមានពី៣៥០០ទៅ៩០០០គ្រាប់។

## ៦- រដូវចេញផ្កា ផ្លែ

ស្ដៅមានផ្កាទ្វេរភេទ ឬភេទឈ្មោល ហើយចំលងលំអងដោយសារសត្វល្អិត។ ស្ដៅចាប់ផ្ដើមមានផ្កាផ្លែនៅអាយុ៥ឆ្នាំ។ ជាទូទៅ ការចេញផ្កាកើតមាននៅក្នុងរដូវប្រាំង ហើយផ្លែទុំនៅក្នុងកំឡុងពេលដើមរដូវវស្សា។ នៅប្រទេសកម្ពុជាស្ដៅចេញផ្កានៅខែមករា ហើយទុំនៅចុងខែមេសា ឬដើមខែឧសភា។ រយៈពេលនៃការលូតលាស់ចេញផ្កាផ្លែអាស្រ័យទៅតាមតំបន់ និងអាកាសធាតុ។ នៅក្នុងតំបន់ដែលមានអាកាសធាតុពីរផ្សេងគ្នា ក៏មានរដូវចេញផ្កាផ្លែពីរផ្សេងគ្នាដែរ ឧទាហរណ៍ នៅក្នុងភូមិភាគខាងត្បូងនៃប្រទេសឥណ្ឌា ការចេញផ្កាកើតមានឡើងពី ២-៥អាទិត្យ មុនតំបន់ភូមិភាគខាងជើងនៃប្រទេស។ ការចេញផ្កាផ្លែយឺតយ៉ាវជាមធ្យម ៤-៥ថ្ងៃ ចំពោះការកើនឡើងនៃរយៈកំពស់១ដឺក្រេ ក្នុងតំបន់ចន្លោះពី ២០-៣០ ដឺក្រេ នៃរយៈទទឹងខាងជើង។ រយៈពេលពីចេញផ្ការហូតដល់គ្រាប់ទុំគឺមានពី ១០-១២ អាទិត្យ។

## ៧- ការប្រមូលគ្រាប់ពូជ

ផ្លែស្ដៅដែលល្អបំផុតត្រូវប្រមូលដោយការបេះពីដើម ដោយហេតុថាការប្រមូលផ្លែដែលជ្រុះលើដីផ្ដល់នូវអត្រាដំណុះទាប។ ពេលល្អបំផុតសំរាប់ធ្វើការប្រមែប្រមូលផ្លែស្ដៅ គឺពេលដែលផ្លែប្រែពណ៌ពីបៃតងទៅជាបៃតងលាយលឿង។ វិធីងាយបំផុតក្នុងការប្រមូលផ្លែគឺការដាក់កំរាលពីក្រោមដើម ហើយធ្វើការប្រមូលផ្លែបន្ទាប់ពីបានច្បូតយកចេញពីមែកដោយដៃ ជម្រុះដោយការអង្រួន ឬដោយវាយមែក។ ដើមដែលមានអាយុប្រមាណ ១០-១២ឆ្នាំ មានទំហំដើមមធ្យមអាចផ្ដល់ទិន្នផលផ្លែស្រស់ពី ៣៥-៥៥ គីឡូក្រាមក្នុងមួយឆ្នាំ ឬ ២៥គីឡូក្រាមផ្លែស្ងួតក្រោយពីបានយកសាច់ចេញ។

## ៨- លទ្ធកម្មគ្រាប់ពូជ និង បញ្ហាជំងឺ

មុនពេលយកគ្រាប់ទៅស្តុកទុក ផ្លែស្ដៅគួរតែត្រូវបានយកសាច់ចេញ ទោះដោយដៃក្ដី ឬដោយឧបករណ៍ក្ដី។ ពេលផ្លែទុំពេញលេញ ត្រូវយកសាច់ចេញភ្លាមដើម្បីចៀសវាងការរលួយជូរ( ឡើងមេ)។ ផ្លែពណ៌បៃតងដែលមិនទាន់ទុំពេញលេញត្រូវទុកបន្ទុំ២-៣ថ្ងៃ មុនពេលយកសាច់ចេញ។ ការយកសាច់ចេញពីផ្លែដែលមិនទាន់ទុំពេញលេញក៏អាចធ្វើបានដែរ ដោយមិនប៉ះពាល់ដល់ដំណុះគ្រាប់ទេ ប៉ុន្តែត្រូវចំណាយពេល និងពលកម្មច្រើន។ គ្រាប់ស្ដៅត្រូវបានចាត់ជាប្រភេទ recalcitrant